Disability Rights California

*បណ្ដាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា (California)*

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

# **# 2: អត្ថន័យសំខាន់ៗស្ដីពីការកាត់ខ្ទង់ថវិកានៃរដ្ឋ (Fact Sheet) សម្រាប់កម្មវិធីផ្ដល់អត្ថប្រយោជន៍លើការអប់រំសិក្សាធិការ K-12 – ថ្ងៃទី6 ខែសីហា ឆ្នាំ2009**

**AB 3632**

ការផ្លាស់ប្ដូរទាំងនេះ ត្រូវបានគេបង្កើតឡើងហើយតាមរយៈយន្តការថវិកានៃរដ្ឋកាលីហ្វ័រញ៉ា។ វិសោធនកម្មទាំងនេះ បានចាប់មានប្រសិទ្ធភាពពីថ្ងៃទី29 ខែកក្កដា ឆ្នាំ2009មក។

## តើច្បាប់បានប្រែប្រួលឬ?

មិនពិតទេ! ច្បាប់មិនបានប្រែប្រួលអ្វីទាំងអស់! បើទោះណាជាខ្ទង់ថវិកាសម្រាប់សេវាកម្មនានាដែលមានកូដ AB 3632 ត្រូវបានគេកាត់បន្ថយ រដ្ឋការនៃរដ្ឋមិនបានផ្លាស់ប្ដូរដល់បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងសេវាកម្មនានាដែលមានកូដ AB 3632 នេះដែរ។ ជួនកាល សេវាកម្មកូដលេខ AB 3632 ត្រូវបានគេហៅថា “AB 2726 services”។ វា គឺជាសេវាតំហែទាំសុខភាពខួរក្បាលដែលបានពីទីភ្នាក់ងារសុខភាពខួរក្បាលថ្នាក់តំបន់ដែលមាននៅតាមមូលដ្ឋានរបស់អ្នក ដែលជា

រឿយៗត្រូវបានគេផ្តល់តាមរយៈកម្មវិធីអប់រំជាលក្ខណៈបុគ្គល (IEP)។ សេវាកម្ម ឬ អត្ថប្រយោជន៍ទាំងនេះ អាចរួមមាននូវៈ វិធីព្យាបាល ការប្រឹក្សានិងគ្រប់គ្រងលើការផ្តល់ថ្នាំព្យាបាល និង អត្ថប្រយោជន៍ផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហាសុខភាពខួរក្បាលដែលទ្រទ្រង់ ឬ គាំពារដល់កុមារដែលអសមត្ថភាពខួរក្បាលទាំងនៅតាមសាលារៀន និង នៅតាមសហាគមន៍មូលដ្ឋាន។

បើទោះជាការផ្តត់ផ្តង់ថវិកា ត្រូវបានគេរួចហើយក៏ក្តី ក៏រដ្ឋនៅតែមិនបានធ្វើឲ្យមានការប្រែប្រួលដល់សិទ្ធិអំណាចនៃបណ្តាទីភ្នាក់ងារសុខភាពខួរក្បាលថ្នាក់តំបន់ដែលតម្រូវថា កុមារត្រូវតែបានទទួលសេវាថែទាំសុខភាពខួរក្បាល។ ដូច្នេះ អត្ថប្រយោជន៍លេខ AB 3632 របស់កូនអ្នក នឹងមិនប្រែប្រួលទេ ប្រសិនបើកូនអ្នកមិនត្រូវបានគេបដិសេធនូវការវាយតម្លៃ ឬ អត្ថប្រយោជន៍លើមូលដ្ឋាននៃការថវិកាទេនោះ។

## តើការកាត់ថវិកាបង្កើតឲ្យមានភាពខុសគ្នាយ៉ាងដូចម្តេច?

ការកាត់នេះ មិនបានរួមបញ្ចូលនូវកំណែនានាដែលមានសារៈសំខាន់ដល់ច្បាប់នោះទេ ដូច្នេះ វាមិនបង្កើតឲ្យមានការប្រែប្រួលមួយណានោះទេ។ អ្នក អាចមើលឃើញមានការប្រែប្រួលតិចតួច ដូចជាការផ្លាស់ប្តូរទីតាំងផ្តល់សេវា ឬ របៀបដឹកជញ្ជូនទៅមក។ លើសពីនេះ ការប្តូរណាមួយមិនត្រូវផ្លាស់ប្តូរនូវសភាពដើម អាជ្ញាយុកាល ឬ ភាពត្រឹមត្រូវនៃអត្ថប្រយោជន៍សម្រាប់កុមារទេ ប្រសិនបើតម្រូវការចាំបាច់នៃកូនអ្នកមានការប្រែប្រួល។

## តើអ្នក ត្រូវធ្វើដូចម្តេច?

ប្រសិនបើអត្ថប្រយោជន៍លេខ AB 3632 នៃកូនអ្នក ត្រូវបានគេផ្លាស់ប្តូរលើបញ្ហាសភាពដើម អាជ្ញាយុកាលដោយសារកាត់ថវិកា សិទ្ធិនៅក្នុងយន្តការដោះស្រាយរបស់អ្នក រក្សានៅដដែល។ អ្នក អាចដាក់ពាក្យស្នើសុំឲ្យមានសវនាការសើរើមួយជាផ្លូវការប្រឆាំងនឹងទីភ្នាក់ងារសុខភាពខួរក្បាលថ្នាក់តំបន់បាន ប្រយោជន៍ដាក់ចំណោទថាអត្ថប្រយោជន៍ដែលគេផ្តល់ឲ្យនោះ មិនត្រឹមត្រូវ។ ដើម្បីស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍លេខ AB 3632 ឬ របៀបប្រឈមការផ្លាស់ប្តូរមិនត្រឹមត្រូវលើអត្ថប្រយោជន៍ AB 3632 នោះ សូមមើលជំពូក6 និង 9 នៃសៀវភៅណែនាំស្តីពីសិទ្ធិ និង ទំនួលខុសត្រូវលើការសិក្សាអប់រំជាពិសេសនៅក្នុងចំណែកនៃការផ្សព្វផ្សាយលើគេហទំព័រ DRC ដែលមានអាសយដ្ឋាន: www.disabilityrightsca.org។

ដោយសារថា ថ្នាក់តំបន់នានាត្រូវបានគេផ្តល់អំណាចឲ្យផ្តល់អត្ថប្រយោជន៍លេខ AB 3632 ថ្នាក់តំបន់នានាមិនបញ្ឈប់ការផ្តល់ដោយស្របច្បាប់ការផ្តល់អត្ថប្រយោជន៍ពិតប្រាកដលេខ AB 3632 ឬ បញ្ឈប់ការផ្តល់អត្ថប្រយោជន៍លេខ AB 3632 ដល់សិស្សមួយចំនួនឡើយ (ឧទាហរណ៍: សិស្សដែលមិនមានការធានារ៉ាប់រងនៃកម្មវិធី Medi-Cal) ដោយសារការកាត់ខ្ទង់ថវិកា។ ក្នុងករណីគេប្រាប់អ្នកថា ថ្នាក់តំបន់របស់អ្នកនឹងមិនធ្វើការផ្តល់អត្ថប្រយោជន៍លេខ AB 3632 ដល់អ្នកណាម្នាក់ទេ ឬ នឹងធ្វើការកាត់អត្ថប្រយោជន៍មួយចំនួនដែលវាបាននិងកំពុងផ្តល់ឲ្យតាមរយៈអត្ថប្រយោជន៍ដែលមានកូដលេខ AB 3632 នោះ សូមមេត្តាទាក់ទង DRC តាមរយៈលេខ: 1-800-776-5746។